# សេចក្តីប្រកាសព័ត៌មាន
## ស្តីពី
# ដំណើរទស្សនកិច្ចសិក្សាស្តីពី
# “ទិដ្ឋភាពច្បាប់ និងការអនុវត្តប្រព័ន្ធ Cash Register នៃភ្នាក់ងារពន្ធដារស៊ុយអែត ( Swedish Tax Agency )”
# របស់គណៈប្រតិភូនៃអគ្គនាយកដ្ឋានពន្ធដារ



© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ

កាលពីថ្ងៃទី២៤ - ២៨ ខែមេសា ឆ្នាំ២០១៧ គណៈប្រតិភូអគ្គនាយកដ្ឋានពន្ធដារកម្ពុជា ដឹកនាំដោយ លោកស្រី អគ្គនាយករង **ម៉ុន នារី** អមដំណើរ ដោយមន្រ្តីជំនាញមួយចំនួន ដែលជាសមាជិកក្រុមការងារគ្រប់គ្រងហានិភ័យ និងវិស័យនៃការទូទាត់សាច់ប្រាក់ (Risk Management and Cash Sector) បានធ្វើទស្សនកិច្ចសិក្សា ស្វែងយល់អំពីទិដ្ឋភាពច្បាប់ និងការអនុវត្តប្រព័ន្ធ Cash Register នៅទីក្រុងហ្គុតធិនបឺក (Gothenburg) ប្រទេសស៊ុយអែត (Sweden) តបតាមការអញ្ជើញរបស់ ទីភ្នាក់ងារពន្ធដារស៊ុយអែត (Swedish Tax Agency) ក្រោមក្របខណ្ឌ គម្រោងជំនួយបច្ចេកទេសសម្រាប់ អគ្គនាយកដ្ឋានពន្ធដារ ដែលផ្តោតលើគោលដៅ ៣ សំខាន់ៗរួមមាន (១). ផ្នែកហានីភ័យនៃការទូរទាត់សាច់ប្រាក់ (Cash Register and Risk Management) (២). ពន្ធលើចំណូលរូបវន្តបុគ្គល (Personal Income Tax) និង (៣). ការពង្រឹងសេវាអ្នកជាប់ពន្ធ (Taxpayer Services) សម្រាប់រយៈពេល ០៣ឆ្នាំ តាមរយៈមូលនិធិរបស់សហភាពអឺរ៉ុប។ តាមរយៈដំណើរទស្សនកិច្ចសិក្សានេះ ក្រុមការងារបានសិក្សាស្វែងយល់អំពីៈ

(១). ជំហានគន្លឹះចាំបាច់មួយចំនួន ដែលគួរត្រូវរៀបចំសម្រាប់ប្រព័ន្ធ Cash Register

(២). បទពិសោធន៍របស់ទីភ្នាក់ងារពន្ធដារស៊ុយអែត ក្នុងការគ្រប់គ្រងវិស័យនៃការទូទាត់សាច់ប្រាក់ (Cash Economy)

(៣). បច្ចេកទេសព័ត៌មានវិទ្យា ដែលចាំបាច់ក្នុងការទ្រទ្រង់ដំណើរការអនុវត្តគម្រោងនេះ និង

(៤). ការធ្វើសវនកម្មសម្រាប់ Cash Register។

ក្នុងឱកាសនៃការបំពេញទស្សនកិច្ចសិក្សា ក្រុមការងារក៏បានពិភាក្សា ដើម្បីឈានទៅបញ្ចប់សេចក្តីព្រាង General Risk Overview ត្រឹមកម្រិតបច្ចេកទេស ដើម្បីទទួលបានជាធាតុចូល និងរៀបចំផែនការសកម្មភាពសម្រាប់ការប្រើប្រព័ន្ធ Cash Register។

ការិយាល័យពន្ធដារតំបន់ហ្គុតធិនបឺក នៃទីភ្នាក់ងារពន្ធដារស៊ុយអែត ជាទីកន្លែងគ្រប់គ្រង និងតាមដានការអនុវត្តប្រព័ន្ធ Cash Register របស់ប្រទេសទេសស៊ុយអែតទាំងមូល។ ក្រុមការងារក៏បានសិក្សាស្វែងយល់ និងទទួលបានមេរៀនបទពិសោធន៍សំខាន់ៗបន្ថែម ស្តីពីគម្រោងត្រួតពិនិត្យផ្ទៃក្នុង



© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ

(Internal Control Projects) នានា ដែលបាននិងកំពុងដាក់ឱ្យអនុវត្តនៅទីភ្នាក់ងារពន្ធដារស៊ុយអែត តាមរយៈបទបង្ហាញជាច្រើនរបស់ជំនាញការក្នុងផ្នែកនីមួយៗ និងកិច្ចពិភាក្សាដែលប្រកបដោយផ្លែផ្កា និងបរិយាកាសស្និទ្ធស្នាល។

លោកស្រីអគ្គនាយករង ប៊ុន នារី បានថ្លែងអំណរគុណដល់តំណាងនៃទីភ្នាក់ងារពន្ធដារស៊ុយអែតប្រចាំតំបន់ ដែលបានជួយសម្របសម្រួល និងរៀបចំដំណើរទស្សនកិច្ចរបស់គណៈប្រតិភូនៃអគ្គនាយកដ្ឋានពន្ធដារកម្ពុជា នៅទីក្រុងហ្គុតធិនបឺក ប្រទេសស៊ុយអែតជាមួយបដិសណ្ឋារកិច្ចយ៉ាងកក់ក្តៅ និងប្រកបដោយជោគជ័យ៕



© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ




© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ



© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ